

ខ្ញុំហាទឈ្មោះប្រាជ្ញរៀននៅថ្នាក់ទី៤«ក»នៅសាលាបឋមសិក្សារាំងទ។

ពុកខ្ញុំទៅធ្វើការនៅភ្នំពេញហាត់ៗ។

ម៉ែខ្ញុំទៅធ្វើការនៅផ្ទះគ្រួសារមួយ

នៅចុងភូមិ។ដូច្នេះខ្ញុំច្រើននៅជាមួយយាយ។



តាំងពីចុងខែធ្នូមក ខ្ញុំត្រូវសិស្សម្នាក់គំរាមយកលុយជារៀងរាល់ថ្ងៃ។

គេឈ្មោះ សាថេ រៀនថ្នាក់ទី៦។

គេហាមខ្ញុំមិនឱ្យនិយាយប្រាប់គេឡើយ។

បើមិនដូច្នេះគេនឹងមិនឱ្យខ្ញុំបានសុខឡើយ។ ខ្ញុំមិនដឹង

ត្រូវធ្វើយ៉ាងណាឡើយ។



ពីពេលនោះមក ខួរក្បាលខ្ញុំដូចជាស្ពឹកៗយ៉ាងម៉េចមិន ដឹងទេ! នៅផ្ទះ
លំហាត់ដែលម៉ែតែងដាក់ឱ្យធ្វើពេលល្ងាចៗ
ក៏ខ្ញុំធ្វើមិនបានល្អដូចមុនៗ។ ឯនៅសាលា
ខ្ញុំស្ដាប់គ្រូពន្យល់មិនចូលសោះ។ តាមធម្មតា រៀនជាមួយអ្នកគ្រូ បីរ៉ាម៉ូ
ខ្ញុំឆាប់យល់ណាស់។




អ្នកគ្រូកំពុងកែកិច្ចការប្រឡងប្រចាំខែមករា។

ពេលនោះគាត់ឃើញកិច្ចការខ្ញុំខុសច្រើន ប្លែកពីធម្មតា។

គាត់ក៏ហៅខ្ញុំមកសួរនាំ ៖ - ប្រាជ្ញ! កូនមានរឿងអី?

ម៉េចបានធ្វើខុសស្ទើរតែគ្រប់សំណួរអីចឹង? - អត់មានអីទេអ្នកគ្រូ!

(ខ្ញុំឆ្លើយតបទាំងព្រលឹងមិននៅក្នុងខ្លួន)



ពេលគាត់សួរ ខ្ញុំហាមាត់និយាយការពិតមិនរួចសោះ។ នេះព្រោះតែខ្ញុំខ្លាច
សាថេ វាយធ្វើហប! ទោះជាយ៉ាងនេះក្ដី អ្នកគ្រូហាក់មិនជឿខ្ញុំទេ។
ព្រោះគាត់បានលួចសួររទើ ដែលមិត្តរួមថ្នាក់ដ៏ ជិតស្និទ្ធរបស់ខ្ញុំ ។
នាងបានលួចសួរខ្ញុំ ពេលកំពុងរៀន ៖ -
ឯងធ្វើអីខុសបានជាអ្នកគ្រូមកសួរខ្ញុំពីម្សិលមិញ ពេលចេញទៅផ្ទះ?



ខ្ញុំមិនបានដឹងថា ទេវី លួចតាមដានខ្ញុំពីពេលណាមកទេ។

ខ្ញុំភ្ញាក់ព្រើតពេលអ្នកគ្រូហៅខ្ញុំទៅសួរ៖ - ប្រាជ្ញ!

ទេវីបានប្រាប់អ្នកគ្រូថា សាថៃ វាយកូនយកលុយ។

ប្រាប់អ្នកគ្រូឲ្យត្រង់មកមើលថា មែន ឬមិនមែន? ឮសម្ដីអ្នកគ្រូ

ខ្ញុំស្ទើរគាំងបេះដូង។ ដោយខ្លាច សាថៃ ធ្វើបាប

ខ្ញុំក៏ឆ្លើយកុហក៖ - មិនពិតទេអ្នកគ្រូ!



ដោយខ្ញុំនិយាយកុហក អ្នកគ្រូហាក់ខឹងយ៉ាងខ្លាំង។ គាត់ក៏ដើរចេញទៅ។ ខ្ញុំលួចតាមមើលគាត់ ឃើញ គាត់ទៅរករឿង សាថេ។ - សាថេ ម៉េចបានជាឯងវាយប្រាជ្ញយកលុយ? - ខ្ញុំមិនបានធ្វើអីចឹងទេ! - បើឯងមិនសារភាព អ្នកគ្រូនឹងប្រាប់លោកនាយក ឱ្យចាត់ការឯងមិនខាន។ (អ្នកគ្រូនិយាយគំរាម)



ខ្ញុំបានលួចមើលមុខអ្នកគ្រូ ឃើញមុខគាត់កាចណាស់។ ចំណែក សាថេ មុខឡើងស្លេកអស់! ប៉ុន្តែគេនៅតែមិន ព្រមសារភាព។ ដោយខឹងពេក អ្នកគ្រូក៏ដើររ៉ូយសំដៅទៅទីចាត់ការ។ ពេលឃើញខ្ញុំ សាថេ ស្ទុះរឹងសំដៅមករកវាយខ្ញុំ។ មុខគេដូចបិសាចអីចឹង។ ខ្ញុំភ័យពេក ក៏ស្រែក និងរត់រកអ្នកគ្រូជួយ។



សាថេ ក្ដាប់ដៃយ៉ាងណែន។ គេខឹងណាស់
ប៉ុន្តែគេមិនហ៊ានវាយខ្ញុំមុខអ្នកគ្រូទេ។ អ្នកគ្រូ
ក៏ហៅពួកយើងទៅទីចាត់ការ។ - មើល៍ សាថេ! ម៉េចហានចង់វាយប្រាជ្ញ?
(នាយកសាលាសួរ សាថេ) - មកពីវាបង្ខូចខ្ញុំថា យកលុយវា។ -
មើលប្រាជ្ញ! សាថេ មានយកលុយពីចៅទេ? (នាយកសាលាសួរខ្ញុំ)



លើកនេះ ខ្ញុំមិនអាចលាក់បានទៀតទេ។ ខ្ញុំខ្លាច សាថេ វាយស្លាប់បើមិននិយាយការពិត។ - បាទលោកគ្រូ! សាថេ យកលុយខ្ញុំរាល់ថ្ងៃ តាំងពីចុងខផ្ទែនូម៉ូលេះ។ - ឯងនិយាយកុហក! ខ្ញុំមិនដែលយកលុយឯងទេ កុំជឿវាលោកគ្រូ! - បើឯងមិនឆ្លើយការពិត។ លោកគ្រូនឹងហៅអាណាព្យាបាលពួកឯងមកជួប។ គ្រូប្រាប់ឲ្យហើយ បើ ប្រាជ្ញ របួសតបែន្តិច ឯងជាអ្នក ទទួលខុសត្រូវ។ ឮទេ?



លោកនាយកបានសរសេរសំបុត្រអញ្ជើញអាណាព្យាបាលសាថេ
និងម្ដាយខ្ញុំ។ នៅព្រឹកថ្ងៃបន្ទាប់ អ្នកគ្រូបានជូនខ្ញុំទៅផ្ទះ។
គាត់ក៏ឆ្លៀតយកសំបុត្រជូនអាណាព្យាបាលខ្ញុំនិងសាថេផង។
ពីព្រោះផ្លូវទៅផ្ទះគាត់ កាត់មុខផ្ទះពួកយើង។ នៅតាមផ្លូវ
គាត់ហាមខ្ញុំមិនឱ្យដើរលេងទេ ព្រោះខ្លាចសាថេ ស្ទាក់វាយ។



ព្រឹកស្អែកឡើង ម៉ែនាំខ្ញុំទៅទីចាត់ការ។ ពេលទៅដល់ ខ្ញុំឃើញអ្នកគ្រូ

បីរ៉ាម៉ូ នាយកសាលា និងលោកគ្រូរបស់ សាថេ ។

ពួកគាត់អង្គុយចាំយើងនៅទីនោះស្រេចហាត់ទៅហើយ។ -

អញ្ជើញចូលមកក្មួយស្រី! (នាយកសាលាហៅម៉ែខ្ញុំចូលក្នុងទីចាត់ការ)

សូមរង់ចាំបន្តិច!



មិនយូរប៉ុន្មាន សាថេ និងប៉ារបស់គេក៏មកដល់។ មុខ សាថេ ដូចជាស្លេកខុសពីធម្មតា។ ម៉ែខ្ញុំភ្ញាក់ព្រើត ពេលបានឃើញ សាថេនិងប៉ារបស់គេមកដែរ។ ពេលជុំគ្នាហើយ លោកនាយកក៏ចាប់ផ្ដើមរៀបរាប់អំពីរឿងរ៉ាវ ។



ពេលបានឮរឿងនេះ ម៉ែខ្ញុំនិយាយអ្វីក៏មិនចេញ។ ចំណែក
ប៉ាសាថខឹងយ៉ាងខ្លាំង។ មិនគួរណា កូនគាត់ធ្វើរឿងអីចឹងសោះ។
គាត់ក៏សួរកូនរកខុសត្រូវ ដោយសម្ដីម៉ាត់ៗ៖ - មើលសាថ!
ប្រាប់ឱ្យត្រង់មកមើល។ កូនបាន ធ្វើអីចឹងមែន ឬអត់ ?



ឮសំណួរភ្លាម សាថចាប់ផ្ដើមស្លេកបបូរមាត់ និយាយទាក់ៗ។ -
មកពីប៉ាយកក្រដាសលំហាត់ខ្ញុំឲ្យទៅវា ហើយសរសេរវាទៀត។
ទើបខ្ញុំចង់ធ្វើហាបវា! - លំហាត់ថ្នាក់ទី៤ហ្នឹង
កូនលែងរៀនទៀតហើយ។ ប៉ាក៏ឱ្យមីងឯងយកឱ្យកូនគាត់រៀន។
មីងឯងមិនសូវចេះអក្សរទេ ទើបប៉ាជួយមើលថា កូនគាត់ធ្វើត្រូវឬខុស។



- ខ្ញុំម៉េចដឹង! បើខ្ញុំឮតែប៉ា និងមីងសរសើរវាតែរហូត។ ថាវាធ្វើលំហាត់ត្រូវ។ - ឥឡូវកូនដឹងហើយ! ឈប់ខឹងឬនៅ ? - សុំទោសប៉ា! កូនខុសហើយ។ - មិនបាច់សុំទោសប៉ាទេ! សុំទោសប្រាជ្ញ និងលោកគ្រូ អ្នកគ្រូទៅ!



គេក៏បែរមកសុំទោសខ្ញុំ និងលោកគ្រូ អ្នកគ្រូទាំងអស់នៅទីនោះ។ គ្រប់គ្នាក៏ទទួលយក ការសុំទោសនេះ។ ព្រោះ សាថេ ក៏ជាសិស្សឆ្នើមម្នាក់របស់សាលាដែរ។ គេក៏មិនដែលធ្វើកំហុសអ្វី លើកលែងតែកំហុសមួយនេះដែរ។ ម្ដាយខ្ញុំរកពាក្យថ្លែងមិនចេញ។ ម្ខាងជាកូនបង្កើត ម្ខាងជាក្មេងដែលគាត់មើលថែតាំងពីតូច។



ពេលឃើញម្ដាយខ្ញុំយំ សាថក៏ពិបាកចិត្តដែរ។ មើលទៅ
គេស្រលាញ់ម្ដាយខ្ញុំណាស់។ គេនិយាយ លួងលោមគាត់។ -
មីងឈប់យំទៅ! ខ្ញុំសន្យាថា មិនធ្វើបាបប្រាជ្ញទៀតទេ !
ហើយពេលមកសាលា ខ្ញុំតាមមើលថែគេជំនួសមីង។



ម៉ែខ្ញុំអរណាស់ពេលបានឮសម្ដីនេះ។ គាត់បាននិយាយអរគុណសាថេ
និងដាស់តឿនខ្ញុំ ៖ - ថ្ងៃក្រោយ ពេលមានរឿងអ្វីមួយ
កូនត្រូវប្រាប់ចាស់ទុំ។ នៅសាលាកូនត្រូវប្រាប់ លោកគ្រូអ្នកគ្រូ។ នៅផ្ទះ
កូនត្រូវប្រាប់ម៉ែ និងលោកយាយ។ កូនមិនត្រូវលាក់ទេ
នេះសំណាងហើយដែលមិនមានរឿងធំ។



ចំណែកខាងសាលាក៏មិនដេញដោលវែងឆ្ងាយដែរ។
លោកនាយកគ្រាន់តែដាស់តឿនសាថេ កុំឱ្យធ្វើដូច្នេះទៀត។
តែបើមានលើកក្រោយសាលានឹងចាត់ការតាមបទបញ្ជាផ្ទៃក្នុងរបស់
សាលាមិនខាន។ ក្រោយពីសម្រួលគ្នាហើយ ប៉ាសាថេ
និងម៉ែខ្ញុំក៏ត្រលប់ទៅផ្ទះវិញទៅ។
ចំណែកពួកយើងក៏ត្រូវចូលរៀនវិញដែរ។



ពេលចេញលេង សាថហោនឱ្យសំបុត្រមកខ្ញុំមួយច្បាប់។ ខ្ញុំក៏បើកមើល ៖ «ប្រាជ្ញឱ្យបង សុំទោស។ បងមិនគួរធ្វើបាបប្អូនសោះ។ ការពិត លុយដែលបងយកពីប្អូន បងបានរក្សាទុកវា។ បងមិនបានចាយវាទេ។ នេះលុយរបស់ប្អូនទាំងអស់ដែលបងយកពីប្អូន។»។



ពេលឃើញលុយរបស់ខ្លួន ខ្ញុំសប្បាយចិត្តណាស់។

ខ្ញុំក៏រាប់គុណមើលឃើញគ្រប់ចំនួន! នេះរាប់ថា ខ្ញុំសន្សំវាចុះ។ ចំណែកវេទី

នាងក៏រីករាយមិនស្ទើរដែរ។ ព្រោះពួកយើងខាន

និយាយលេងជាមួយគ្នាយូរមកហើយ។

នៅមានរឿងល្អជាច្រើនទៀតដែលខ្ញុំត្រូវរៀបរាប់ប្រាប់អ្នកទាំងអស់គ្នា។

ប៉ុន្តែដោយសារពេលវេលាមិនអំណោយផល

ខ្ញុំសូមគោរពលាតប៉ុណ្ណោះសិនចុះ។

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org To read more books like this and get further information, visit letsreadasia.org .
Original Story Prach and Sathae, author: Huot Sarith . illustrator: Ouk Ratha. Published by The Asia Foundation, https://www.letsreadasia.org © The Asia Foundation. Released under CC BY 4.0.
This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.
org/licenses/by/4.0/



# ប្រាជ្ញ និង សាថេ

Huot Sarith